# អរិយធម៌ឌីលម៉ុន

ឌីលម៉ុនគឺជាឈ្មោះដែលសំដៅលើអរិយធម៌បុរាណមួយ ដែលស្ថិតនៅខាងជើងនៃប្រទេសបារ៉ែន (Bahrain)។ អរិយធម៌នេះមានរាជធានីសំខាន់មួយឈ្មោះ ថា Qal'at al-Bahrain។ តាមរយៈវត្ថុសិល្បៈដែលបានរកឃើញនៅតំបន់នោះ បានបង្ហាញឱ្យឃើញពីតឹកតាងនៃការតាំងទីរស់នៅរបស់មនុស្សតាំងពី២៣០០ឆ្នាំមុនគ.ស.មកម្ល៉េះ។[១]

ឌីលម៉ុនគឺជាអរិយធម៌ដែលសំខាន់មួយនៅក្នុងឧបទ្វីបអារ៉ាប់។ Qal'at al-Bahrain ត្រូវបានអ្នកស្រាវជ្រាវដឹងថាជាទីក្រុង និងជាបេះដូងនៃអរិយធម៌ឌីលម៉ុន (Ancient Harbour and Capital of Dilmun)។ អរិយធម៌នេះមានទំនាក់ទំនងជាមួយនឹងអរិយធម៌ផ្សេងៗ រួមមាន Elam នៅអ៊ូម៉ង់ និងAlba នៅស៊ីរី និង Haittan នៅទួគីជាដើម។[២]

ស្ថានីយបុរាណវិទ្យា Qal'at al-Bahrain ត្រូវបានរកឃើញនៅអំឡុងឆ្នាំ ១៩៥៤ ដោយអ្នកស្រាវជ្រាវជនជាតិដាណាម៉ាក។ ចាប់តាំងពីឆ្នាំ ១៩៧៧មក វិទ្យាស្ថានស្រាវជ្រាវជាតិបារាំងចាប់ផ្តើមធ្វើការកំណាយនៅទីតាំងក្រុងនេះ (CNRS) និងបានឃើញមានស្រទាប់ដីជាបីសម័យកាលធំៗ ដោយមានសម័យកាលឌីលម៉ុន, សម័យ Hellenistic (ស.វ.ទី៣មុនគ.ស.ទៅ ស.វ. ទី៣នៃគ.ស.) និងសម័យកាលអ៊ីស្លាម( ស.វ.ទី១៣ នៃគ.ស. ទៅ ស.វ.ទី១៧ នៃគ.ស.)។ ទិន្នន័យដែលបានយកមកបង្ហាញ គឺតាមរយៈការសិក្សាលើរុក្ខជាតិ ឆ្អឹងសត្វ សំបកគ្រំ ខ្យង និងសំណល់វត្ថុសិល្បៈផ្សេងៗទៀត។[៣]

ចាប់តាំងពីទិន្នន័យនៃការកំណាយឆ្នាំ ១៩៥៤ រហូតដល់បច្ចុប្បន្ន អ្នកស្រាវជ្រាវដាណាម៉ាក បារាំង បារ៉ែន បានបន្តរកឃើញនូវវត្ថុសិល្បៈនៃអរិយធម៌នេះជាច្រើន។ ការរកឃើញវត្ថុសិល្បៈទាំងនោះ គឺជាពន្លឺថ្មី និងជាពត៌មានថ្មីមួយ សម្រាប់បង្ហាញអំពីអរិយធម៌

---

[១] https://whc.unesco.org/en/list/1192

[២] https://www.bbc.com/news/science-environment-22596270

[៣] ibid

អត្ថបទដោយ៖ អេង តុលា

ឌីលម៉ុន។ វត្ថុសិល្បៈទាំងនោះរួមមាន វត្ថុអំពីដីដុត លោហធាតុ ឧបករណ៍ប្រើប្រាស់ផ្សេងៗ គ្រឿងអលង្ការផ្សេង និងជាពិសេសការរកឃើញស្ថានីយកប់សព ។

តាមរយៈការសិក្សាលើកាបូន១៤លើវត្ថុសិល្បៈទាំងនោះ អ្នកស្រាវជ្រាវបានលើកឡើងថាអរិយធម៌នេះកកើតឡើងនៅរវាងឆ្នាំ២០០០ ទៅ ៥០០មុនគ.ស.។[៤]

ក្រៅពីស្ថានីយបុរាណវិទ្យា Qal’at al-Bahrain អ្នកស្រាវជ្រាវក៏បានរកឃើញនូវស្ថានីយមួយផ្សេងទៀតដែលហៅថា Dilmun Burial Mounds។ Dilmun Burial Mounds គឺជាកន្លែងបញ្ចុះសពនៅក្នុងអរិយធម៌ឌីលម៉ុន។ ស្ថានីយនេះមានអាយុកាលចន្លោះ ២២០០ រហូតដល់១៧៥០មុនគ.ស. ពោលគឺអាចមុននឹងអរិយធម៌ឌីលម៉ុនទៅទៀត។ នៅក្នុងស្ថានីយនេះ អ្នកស្រាវជ្រាវឃើញមានប្រមាណជាង១១៧៧៤ ទួលសព ដោយក្នុងនោះមានប្រមាណ១៧ ដែលដឹងថាជាផ្នូររបស់ស្តេច។[៥]

សម្រាប់វត្ថុដែលបានរកឃើញទាំងនោះ រដ្ឋាភិបាលបារ៉ែនបានកសាងជាសារមន្ទីរស្ថិតនៅក្បែរស្ថានីយបុរាណវិទ្យា Qal’at al-Bahrain សម្រាប់ទស្សនា និងស្វែងយល់អំពីពត៌មាននៃការកសាងស្ថានីយ និងអរិយធម៌ឌីលម៉ុន។ អ្នកស្រាវជ្រាវពុំដឹងអំពីមូលហេតុច្បាស់លាស់នៃការដួលរលំនៃអរិយធម៌ឌីលម៉ុនទេ ប៉ុន្តែប្រហែលមកពីការប្រែប្រួលអាកាសធាតុក្នុងតំបន់ និងមានការឈ្លានពីអរិយធម៌ដទៃទៀត និងមានកត្តាផ្សេងៗដែលធ្វើឱ្យអរិយធម៌ចំណាស់នេះដួលរលំ។

សរុបមកឌីលម៉ុន គឺជាអរិយធម៌ដែលចាស់មួយដែរ នៅក្នុងតំបន់មជ្ឈិមបូព៌ាដែលជាតំបន់កកើតនៃអរិយធម៌មុនៗនៅលើពិភពលោក ដោយក្នុងនោះរួមមាន មេសូម៉ូតាមី ឥណ្ឌូស ជាដើម។ តាមរយៈទិន្នន័យបុរាណវិទ្យា ទាំងនោះ បានបង្ហាញថា ទីក្រុងនៃអរិយធម៌នេះត្រូវបានបោះបង់ចោលនៅស.វ.ទី ១៧នៃគ.ស. (Lombard 2016)។

[៤] https://hal.archives-ouvertes.fr/hal-01842044/file/LOMBARD_QB_Museum_2016.pdf

[៥] https://whc.unesco.org/en/list/1542

អត្ថបទដោយ៖ អេង តុលា




រូបលេខ១-២៖ ផែនទីនៃអរិយធម៌ឌីលម៉ុន និងទីក្រុង Qal’at al-Bahrain

ប្រភព៖ Lombard 2016





រូបលេខ៣-៤៖ រូបថតទីក្រុង Qal’at al-Bahrain ពីលើអាកាស

ប្រភព៖ Lombard 2016







រូបលេខ៥ ៖ រូបថតវាលបញ្ចុះសព Bahrain ពីលើអាកាស

ប្រភព៖ https://www.pinterest.com/pin/

រូបលេខ ៦៖ អំឡុងពេលកំណាយនៅ Dilmun Burial Mounds ក្នុងឆ្នាំ ២០១៦

ប្រភព៖ Lombard 2016



រូបលេខ ៧៖ គ្រោងឆ្អឹងដែលបានរកឃើញ

ប្រភព៖ Lombard 2016



រូបលេខ៨ ៖ សារមន្ទីរនៅក្បែរ Qal'at al-Bahrain

ប្រភព៖ Lombard 2016

## ឯកសារយោង


https://whc.unesco.org/en/list/1192

https://www.bbc.com/news/science-environment-22596270

https://hal.archives-ouvertes.fr/hal-01842044/file/LOMBARD_QB_Museum_2016.pdf


អត្ថបទដោយ៖ អេង តុលា